# 【សំខាន់】 ប្រការប្រុងប្រយ័ត្នពេលធ្វើតេស្ត <អ្វីដែលត្រូវពិនិត្យមុនថ្ងៃប្រលង>

អង្គការវាយតម្លៃជំនាញពលករបរទេសក្នុងវិស័យចំណីអាហារ

ពេលទៅដល់មណ្ឌលប្រឡង ត្រូវវាស់កម្ដៅខ្លួន។ បើមានអ្នកដែលកម្ដៅខ្លួនចាប់ពី 37.5 $^{O}$C ឡើង អ្នកអនុវត្តការបណ្ដុះបណ្ដាលនោះនឹងត្រូវបានស្នើសុំឲ្យត្រឡប់ទៅវិញទាំងអស់គ្នាដែលរួមទាំងអ្នកធ្វើតេស្ត អ្នកអមដំណើរ។ (តម្រូវឲ្យធ្វើតេស្តក្រោយពេលសម្របសម្រួលកាលវិភាគប្រឡងឡើងវិញ)

**ក្រោយវាស់កម្ដៅខ្លួនរួច សូមពន្យល់អំពី【ចំណុចប្រុងប្រយ័ត្នក្នុងការធ្វើតេស្ត】នេះ ដោយពន្យល់ចំណុចទី1និងទី2 ទៅអ្នកធ្វើតេស្ត និងចំណុចទី3 ទៅអ្នកអមដំណើរ។**

**1. អំពីការផ្លាស់សម្លៀកបំពាក់ និងការគ្រប់គ្រងរបស់មានតម្លៃ**

(1) របស់មានតម្លៃត្រូវគ្រប់គ្រងដោយខ្លួនឯង។ ពេលធ្វើដំណើរត្រូវយកអីវ៉ាន់ទៅតាមរៀងៗខ្លួន។
(2) សូមប្រយ័ត្នកុំឲ្យមានភ្លេចឬជ្រុះបាត់អីវ៉ាន់។
(3) សូមបិទឧបករណ៍ទំនាក់ទំនងទាំងអស់ដូចជាស្មាតហ្វូនជាដើម ហើយទុកក្នុងកាបូប។ អ្នកដែលមិនអាចបិទបាន សូមផ្ញើនៅអ្នកអមដំណើរ។
(4) សូមដោះចេញគ្រឿងអលង្ការទាំងអស់ដូចជា នាឡិកាដៃ ចិញ្ចៀន ខ្សែក ក្រវិល ជាដើម ហើយដាក់ក្នុងកាបូប។
(5) ពេលផ្លាស់ជាសម្លៀកបំពាក់ការងារ សូមផ្លាស់តែអាវក្រៅនិងខោប៉ុណ្ណោះ។ (ពេលប្រឡង នឹងត្រូវពាក់មួកនិងស្រោមដៃ។ ឥឡូវសូមកុំទាន់ពាក់)
(6) ក្នុងហោប៉ៅសម្លៀកបំពាក់ការងារ សូមកុំដាក់អ្វីទាំងអស់។
(7) សូមផ្លាស់សម្លៀកបំពាក់នៅកន្លែងដែលណែនាំដោយអនុរក្ស។
(8) សូមកុំប្រើបង្គន់ដែលមានសញ្ញាកៅអីរុញ។ ការនិយាយគ្នាឬផ្លាស់សម្លៀកបំពាក់នៅក្នុងបង្គន់ក៏ត្រូវបានហាមឃាត់ដែរ។
(9) ក្នុងមណ្ឌលប្រឡង ការថតរូបត្រូវបានហាមឃាត់។

**2. ប្រការប្រុងប្រយ័ត្នពេលកំពុងប្រឡង**

(1) ហាមមើលចម្លើយរបស់អ្នកធ្វើតេស្តផ្សេង។
(2) ហាមមើលឯកសារមេរៀន សៀវភៅកត់ត្រា កំណត់ត្រាជាដើម។
(3) ហាមនិយាយម្នាក់ឯងឬនិយាយជាមួយអ្នកជុំវិញ។
(4) ហាមចាកចេញពីកៅអី។
(5) ហាមចម្លងវិញ្ញាសាប្រឡងដាក់លើបង្កាន់ដៃប្រឡងឬលើដៃជាដើម។
(6) ហាមប្រាប់ចម្លើយឬជួយអ្នកធ្វើតេស្តផ្សេង។
(7) ពេលកំពុងប្រឡង សូមធ្វើតាមការណែនាំរបស់អនុរក្ស។ ហាមធ្វើបន្តទៅមុខមុនពេលមានការណែនាំពីអនុរក្ស។ សកម្មភាពតាមតែចិត្តឯងនឹងត្រូវបានដកពិន្ទុ។
(8) បើមានសកម្មភាពមិនត្រឹមត្រូវឬសកម្មភាពបង្កបញ្ហា នឹងត្រូវបាត់បង់សិទ្ធិប្រឡង។ ក្នុងករណីនោះនឹងមិនអាចប្រឡងឡើងវិញបានទេ។ សូមប្រុងប្រយ័ត្នឲ្យបានគ្រប់គ្រាន់។
(9) ពេលកំពុងប្រឡង បើមិនស្រួលខ្លួន សូមប្រាប់អនុរក្សដោយកុំប្រឹងហួសហេតុ។
(10) ក្នុងករណីមានគ្រោះមហន្តរាយដូចជារញ្ជួយដីឬអគ្គីភ័យជាដើម សូមធ្វើតាមការណែនាំរបស់អនុរក្សដោយកុំជ្រួលច្របល់។

**3. សំណូមពរទៅកាន់អ្នកអមដំណើរ**

(1) ទូរសព្ទស្មាតហ្វូនសូមដាក់ឲ្យគ្មានសំឡេងរោទិ៍។
(2) សំរាមដែលកើតមានក្នុងការប្រឡងធ្វើម្ហូប សូមយកត្រឡប់ទៅចោលនៅក្រុមហ៊ុន។
(3) សូមរង់ចាំនៅកន្លែងរង់ចាំដើម្បីឲ្យអាចទាក់ទងបានក្នុងគ្រាអាសន្ន។ ពេលចាកចេញពីកន្លែងអង្គុយ សូមប្រាប់អនុរក្ស។